រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

# អនុក្រឹត្យលេខ ២១ អនក្រ.បក
# ស្តីពីការកំណត់រយៈពេលបំពេញការងារប្រចាំសប្តាហ៍ របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាព្រះក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១ :** មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារចំនួន ៥ ថ្ងៃ ក្នុងមួយសប្តាហ៍ និងត្រូវបានអនុញ្ញាតអោយឈប់សំរាកការងារចំនួន ២ ថ្ងៃ ក្នុងមួយសប្តាហ៍ គឺថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ ។

**មាត្រា ២ :** មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារអោយបានទៀងទាត់ តាមរយៈពេលដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ និងធ្វើ ការក្នុងមួយថ្ងៃចំនួន ៨ ម៉ោង គឺ ÷

–ព្រឹកពីម៉ោង ៧ និង ០០ នាទី ដល់ម៉ោង ១១ និង ៣០ នាទី

–ល្ងាចពីម៉ោង ១៤ និង ០០ នាទី ដល់ម៉ោង ១៧ និង ៣០ នាទី

**មាត្រា ៣** : រយៈពេលបំពេញការងារប្រចាំសប្តាហ៍របស់សាស្ត្រាចារ្យ គ្រូបង្រៀន បុគ្គលិកសិក្សាតាមគ្រឹះស្ថានសិក្សានានា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

**មាត្រា ៤** : ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ សារាចរ និងលិខិតបទដ្ឋានផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល និងអភិបាលគ្រប់ខេត្ត–ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ២២ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មការចំរុះជំរៀសការអតិថជន ក្នុងក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា